# ការវិវឌ្ឍន៍ក្នុងរយៈពេល៨ឆ្នាំ ២០១៦-២០២៣



# ការយល់ឃើញរបស់ថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីព អំពីសេរីភាពមូលដ្ឋាននៅកម្ពុជា

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន គឺជាគម្រោងធ្វើការឃ្លាំមើលលំហសង្គមស៊ីវិលនៅកម្ពុជា ជាពិសេសឃ្លាំមើលទៅលើលទ្ធភាពរបស់បុគ្គលដែលអាចអនុវត្តសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ (សេរីភាពមូលដ្ឋាន)។ គម្រោងធ្វើការស្ទង់មតិប្រចាំឆ្នាំ ជាមួយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងថ្នាក់ដឹកនាំសហជីព ដើម្បីវាស់ស្ទង់ថាតើថ្នាក់ដឹកនាំនីមួយៗមានសេរីភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួនកម្រិតណា។

ចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលចូលរួមការស្ទង់មតិ ចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២៣




នៅឆ្នាំ២០២៣ គម្រោងបានស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពចំនួន ១៥៩ តំណាងឱ្យអង្គការសង្គមស៊ីវិល និងសហជីពដែលអនុវត្តសកម្មភាពនៅក្នុងប្រទេសកម្ពុជា (អង្គការសង្គមស៊ីវិលចំនួន ១០៤ និងសហជីពចំនួន៥៥)។

ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលរាយការណ៍ថាការបង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ និងសហជីព ត្រូវបានរឹតត្បិត




ទិន្នន័យប្រមូលបានក្នុងឆ្នាំ២០២៣ បង្ហាញថាមានការថយចុះចំនួន ៣% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលរាយការណ៍ថាខ្លួនបានប្រឈមនឹងការរឹតត្បិតក្នុងការបង្កើតជាបណ្តាញ សម្ព័ន្ធ សហព័ន្ធ និងសហជីព។ ការរក្សាបរិយាកាសដែលធ្វើឱ្យសង្គមស៊ីវិល និងសហជីព អាចបង្កើតបណ្តាញនិងសម្ព័ន្ធបានដោយសេរីពិតជាមានសារៈសំខាន់ខ្លាំងណាស់ដោយសារតែវាស្ថិតក្នុងចំណោមសិទ្ធិក្នុងការបង្កើតសមាគមដែលមានចែងក្នុងច្បាប់ជាតិនិងច្បាប់អន្តរជាតិ។

ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលរាយការណ៍ថារដ្ឋាភិបាលបានតាមដានសកម្មភាពរបស់ខ្លួន




ចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលឆ្លើយថា 'បាទ/ចាស' ទៅនឹងសំនួរដែលសួរថា តើស្ថាប័នរបស់អ្នកធ្លាប់ប្រឈមនឹងឃ្លាំមើលឬតាមដានពីរដ្ឋាភិបាលឬទេ មានការថយចុះចំនួន៨% គឺពី៤៥% នៅឆ្នាំ២០២២ មកត្រឹម ៣៧% ក្នុងឆ្នាំ២០២៣។




ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលយល់ថាការឃ្លាំមើលរបស់រដ្ឋាភិបាលហាក់ហួសហេតុមានការថយចុះចំនួន៦% ពី៦៤% នៅឆ្នាំ២០២២ មកត្រឹម៥៨% ក្នុងឆ្នាំ២០២៣។ នេះជាការវិវឌ្ឍវិជ្ជមានមួយដែលនៅឆ្នាំ២០២៣ គឺជាឆ្នាំដំបូងមានការកត់ត្រាចំនួនតិចបំផុតចាប់តាំងពីការចាប់ផ្តើមដំបូងរបស់គម្រោង តែក៏មិនគួរមិនអើពើនោះដែរ នៅពេលការពិតចំនួនលើសពីពាក់កណ្តាលនៃថ្នាក់ដឹកនាំទាំងនោះមានអារម្មណ៍ថាការឃ្លាំមើលសកម្មភាពនោះហាក់ហួសហេតុ។




នៅក្នុងឆ្នាំ២០២៣ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលរាយការណ៍ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីមានការកើនឡើងត្រឹម៦% ពោលគឺពី ៥៤% នៅក្នុងឆ្នាំ២០២២ ទៅ៦០% នៅក្នុងឆ្នាំ២០២៣។ មានការកើនឡើងចំនួន៣% ក្នុងចំណោមថ្នាក់ដឹកនាំដែលមានអារម្មណ៍ថាមានសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន ពោលគឺមានចំនួន ៥៨% ក្នុងឆ្នាំ២០២៣។ ផ្ទុយពីការកើនឡើងបន្តិចបន្តួចនេះ ចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនឹងសហជីព ដែលរាយការណ៍ថាមានសេរីភាពក្នុងការបង្ហាញការយល់ឃើញរបស់ពួកគេមានការធ្លាក់ចុះចាប់តាំងពីឆ្នាំ២០១៧ មកម្ល៉េះ នេះអាចបណ្តាលមកពីការចាត់វិធានការមកលើស្ថាប័នសារព័ត៌មានឯករាជ្យ និងការកើនឡើងចំនួនបុគ្គលដែលទទួលរងការប្រឈមផ្នែកច្បាប់ដោយសារការអនុវត្តសេរីភាពនេះ។




ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព ដែលរាយការណ៍ថាមានអារម្មណ៍ថាពុំមានសុវត្ថិភាពក្នុងការបញ្ចេញមតិយោបល់របស់ពួកគេតាមប្រព័ន្ធផ្សព្វផ្សាយមានការថយចុះមកត្រឹម១៦% នៅក្នុងឆ្នាំ២០២៣។ គួរចាប់អារម្មណ៍ថា នេះជាភាគរយតិចបំផុតចាប់តាំងពីការចាប់ផ្តើមកត់ត្រារបស់គម្រោង។




ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលរាយការណ៍ថាជានិច្ចកាល ឬជាប្រចាំតែងរឹតត្បិតខ្លួនឯង ដោយសារតែភ័យខ្លាចការគុំកួនបានថយចុះ៥% នៅក្នុងឆ្នាំ២០២៣ ពោលគឺ៤៣%។ ខណៈតួលេខនៅក្នុងឆ្នាំ២០២៣ មានការថយចុះ បានបង្ហាញពីចំណុចគួរឱ្យព្រួយបារម្ភដែលចំនួនភាគរយនៃអ្នកឆ្លើយតបបានរាយការណ៍ពីការរឹតត្បិតខ្លួនឯង។ អង្គការសង្គមស៊ីវិលមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងសង្គមប្រជាធិបតេយ្យដោយសារតែពួកគេតំណាងឱ្យសម្លេងសមូហភាពនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។




នៅក្នុងឆ្នាំ២០២៣ ៥៤% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលមានអារម្មណ៍ថា ស្ថាប័នរបស់ពួកគេត្រូវបានរដ្ឋាភិបាលទទួលស្គាល់ថាជាដៃគូអភិវឌ្ឍន៍ស្របច្បាប់បានថយចុះចំនួន ៣% ពីឆ្នាំ២០២២។ ផ្ទុយទៅវិញ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាត្រូវបានទទួលស្គាល់ថាជាដៃគូអភិវឌ្ឍន៍ដែលមានសមត្ថភាពមានការកើនឡើងចំនួន ៣% នៅក្នុងឆ្នាំ២០២៣។

ភាគរយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលរាយការណ៍ថាបានចូលរួម
នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងដំណើរការតាក់តែងច្បាប់ជាមួយរដ្ឋាភិបាល




ទិន្នន័យបានបង្ហាញពីការធ្លាក់ចុះភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលរាយការណ៍ទាំងធ្លាប់បានចូលរួម ‘ញឹកញាប់ណាស់’ និង ‘ញឹកញាប់’ នៅក្នុងដំណើរការតាក់តែងច្បាប់ ដែលថយចុះពី៨% នៅក្នុងឆ្នាំ២០២២ មកត្រឹម៤% នៅឆ្នាំ២០២៣។ ការវិវឌ្ឍន៍វិជ្ជមាននោះគឺចំនួនអ្នកឆ្លើយតប មានត្រឹមតែ២៨% បានរាយការណ៍ថា ‘មិនដែលសោះ’ ក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តនិងដំណើរការតាក់តែងច្បាប់ បើប្រៀបធៀបនឹងឆ្នាំ២០២២ ដែលមានអ្នកឆ្លើយតប ៣៤% និងនៅឆ្នាំ២០២០ មានអ្នកឆ្លើយតបបែបនេះចំនួន៥៨%។ ខណៈដែលអង្គការសង្គមស៊ីវិលបានចូលរួមក្នុងកិច្ចពិគ្រោះយោបល់នៅក្នុងដំណើរការតាក់តែងច្បាប់ ឧទាហរណ៍សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដោយឡែកអង្គការសង្គមស៊ីវិលនៅតែត្រូវបានផាត់ចេញពីការជជែកពិភាក្សានៅក្នុងដំណើរការតាក់តែង ដូចជាច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះ ឆ្នោតដែលបានអនុម័តនៅក្នុងខែកក្កដា ឆ្នាំ២០២៣ ដោយមិនមានការពិភាក្សា។



មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

SOLIDARITY CENTER

សមាគមអាដហុក
ADHOC

ខែមីនា ឆ្នាំ២០២៤

CC BY NC SA